# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា

-----------

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី ២១ ខែមិថុនា ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផល ទំនិញ និងសេវា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច

- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១២ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកំណត់ និងការគ្រប់គ្រងទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីការត្រួតពិនិត្យភូតគាមអនាម័យ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ
- បានការឯកភាពពីគណៈរដ្ឋមន្ត្រី នាសម័យប្រជុំពេញអង្គ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៤

## សំរេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលដៅរៀបចំការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ដើម្បីធានាសន្តិសុខ និងសុវត្ថិភាពប្រតិបត្តិការវិស័យអាកាសចរស៊ីវិល ស្ថិរភាព សណ្តាប់ធ្នាប់សាធារណៈ ការធ្វើអាជីវកម្ម ការរកចំណូលចូលថវិការដ្ឋ និងកិច្ចការពារសុខុមាលភាព ជូនអ្នកដំណើរជាតិ និងអន្តរជាតិ។

## ជំពូកទី ២

## រចនាសម្ព័ន្ធ

**មាត្រា ២.-**

អាកាសយានដ្ឋានអន្តរជាតិ ត្រូវបានដឹកនាំ និងគ្រប់គ្រងដោយគណៈកម្មាធិការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិ ដែលមានអង្គភាព ជាសេនាធិការ :

- ក្រុមប្រតិបត្តិការសន្តិសុខ អាកាសយានដ្ឋានអន្តរជាតិ
- និងក្រុមត្រួតពិនិត្យច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិ ។

## ជំពូកទី ៣

## គណៈកម្មាធិការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិ

**មាត្រា ៣.-**

គណៈកម្មាធិការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិ មានសមាសភាព :

| | | |
|---|---|---|
| - | រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| - តំណាង | ក្រសួងមហាផ្ទៃ | អនុប្រធាន |
| - តំណាង | អគ្គស្នងការដ្ឋាននគរបាលជាតិ | អនុប្រធាន |
| - តំណាង | អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ | អនុប្រធាន |
| - តំណាង | រដ្ឋលេខាធិការដ្ឋាននៃអាកាសចរស៊ីវិល | អនុប្រធានប្រចាំការ |
| - តំណាង | ក្រសួងការពារជាតិ | សមាជិក |
| - តំណាង | ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| - តំណាង | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| - តំណាង | ក្រសួងទេសចរណ៍ | សមាជិក |
| - តំណាង | ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ | សមាជិក |
| - តំណាង | គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ | សមាជិក |
| - តំណាង | គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ | សមាជិក |
| - តំណាង | បញ្ជាការដ្ឋានកងទ័ពជើងអាកាស | សមាជិក |
| - តំណាង | បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |

- តំណាង ក្រុមប្រឹក្សាអ្នកច្បាប់ សមាជិក
- តំណាង សាលាខេត្ត-ក្រុង ដែលមានអាកាសយានដ្ឋានអន្តរជាតិ សមាជិក
- តំណាង ទីចាត់ការគយនិងរដ្ឋាករ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក
- តំណាង នាយកដ្ឋានកាំកុងត្រូល នៃក្រសួងពាណិជ្ជកម្ម សមាជិក
- ប្រធានក្រុមប្រតិបត្តិការសន្តិសុខអាកាសយានដ្ឋានអន្តរជាតិ សមាជិក
- ប្រធានក្រុមត្រួតពិនិត្យច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិ សមាជិក

សមាសភាពនៃគណៈកម្មាធិការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិ ត្រូវកំណត់ដោយសេចក្តីសំរេចរបស់រាជរដ្ឋាភិបាល ។

**មាត្រា ៤.-**

គណៈកម្មាធិការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិ ជាស្ថាប័នតំណាងរាជរដ្ឋាភិបាល ទទួលបន្ទុកការងារដឹកនាំ និងគ្រប់គ្រងផ្ទាល់ លើអាកាសយានដ្ឋានអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា មានសិទ្ធិ និងភារកិច្ច :

- រៀបចំកសាងផែនការមេ ស្តីពីកិច្ចការពារសន្តិសុខ និងសុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ នៅតាមអាកាសយានដ្ឋានអន្តរជាតិ ដោយផ្អែកលើសន្ធិសញ្ញា អនុសញ្ញា កិច្ចព្រមព្រៀង ដែលពាក់ព័ន្ធនឹងវិស័យសន្តិសុខអាកាសចរស៊ីវិលទ្វេភាគី អន្តរជាតិ និងស្របតាមស្ថានភាពជាក់ស្តែងនៅព្រះរាជាណាចក្រកម្ពុជាដើម្បីសុំការសំរេចពីរាជរដ្ឋាភិបាល
- ចាត់ចែងផ្សព្វផ្សាយ និងប្រគល់ភារកិច្ចអោយកំលាំងមានសមត្ថកិច្ចក្រោមឱវាទ និងស្ថាប័នពាក់ព័ន្ធ ចាត់តាំងអនុវត្តតាមផែនការមេ ស្តីពីកិច្ចការពារសន្តិសុខ និងសុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ នៅតាមអាកាសយានដ្ឋានអន្តរជាតិ
- លើកវិធានការសំរាប់អនុវត្តចំពោះមុខ សំដៅបង្កើនកិច្ចការពារសុវត្ថិភាព ដល់វិស័យអាកាសចរស៊ីវិល ដែលធ្វើការហោះហើរឆ្លងកាត់ និង ឬ ចុះចតជាលក្ខណៈពាណិជ្ជកម្ម និងមិនមែនពាណិជ្ជកម្ម នៅក្នុងដែនអាកាស និងអាកាសយានដ្ឋានអន្តរជាតិទាំងឡាយ នៃព្រះរាជាណាចក្រកម្ពុជា ក្នុងពេលដែលពុំទាន់បានកសាងផែនការមេ ស្តីពីកិច្ចការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ នៅតាមអាកាសយានដ្ឋានអន្តរជាតិ
- ជំរុញក្រុមហ៊ុនសម្បទានអាកាសយានដ្ឋានអន្តរជាតិ អោយខិតខំបំពាក់មធ្យោបាយ និងឧបករណ៍ទំនើបៗ ក្នុងការត្រួតពិនិត្យលើអ្នកដំណើរ សំភារៈ ប័ណ្ណ និងទំនិញ ក្នុងស្រុក និងអន្តរជាតិ ស្ថានីយ៍នៃបន្ទប់ទទួលភ្ញៀវពិសេស ចំណតអាកាសយាន ចំណតរថយន្ត និងទីតាំងនានា ក្នុងអាកាសយានដ្ឋានអន្តរជាតិ

- អញ្ជើញតំណាងក្រុមហ៊ុនសម្បទានអាកាសយានដ្ឋានអន្តរជាតិ ក្រុមហ៊ុនអាកាសចរ និងស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត មកចូលរួមប្រជុំពិភាក្សាដោះស្រាយ លើរាល់បញ្ហាដែលកើតមានឡើងជាយថាហេតុ ក្នុងករណីចាំបាច់
- ធ្វើការកំណត់ តាមដាន និងលើកយោបល់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសំរេចលើករណីសុំចុះចតរបស់អាកាសយានជាលក្ខណៈពិសេសដោយរួចពន្ធ ការសុំចុះចតរបស់អាកាសយានក្នុងគ្រាមានអាសន្ន ភាពមិនប្រក្រតី នៃសភាពការណ៍សន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ និងគ្រោះមហន្តរាយ ដែលកើតឡើងជាយថាហេតុនៅក្នុងដែនអាកាស និងក្នុងអាកាសយានដ្ឋានអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា
- រៀបចំធ្វើការហ្វឹកហ្វឺន បណ្តុះបណ្តាល បំពាក់បំប៉ន និងផ្សព្វផ្សាយពត៌មាន ដល់មន្ត្រីមានសមត្ថកិច្ច និងកំលាំងការពារសន្តិសុខ នៅតាមអាកាសយានដ្ឋានអន្តរជាតិនីមួយៗ ដើម្បីពង្រឹងពង្រីកសមត្ថភាពជំនាញធ្វើការងារ និងពង្រឹងការអនុវត្តច្បាប់ការងារចំពោះកម្មករ និងនិយោជិត
- ពិនិត្យ និងសំរេច ក្នុងការផ្តល់ប័ណ្ណចេញ-ចូលអាកាសយានដ្ឋានអន្តរជាតិ សំរាប់រថយន្ត និងសំរាប់មន្ត្រីរាជការ នៃក្រសួង ស្ថាប័នរដ្ឋ និងភ្នាក់ងារក្រុមហ៊ុនឯកជន
- ធ្វើការប្រជុំមួយឆមាសម្តង ហើយក្នុងករណីចាំបាច់ អាចបើកប្រជុំជាវិសាមញ្ញ
- បូកសរុបសភាពការណ៍ និងសកម្មភាពការងារ នៅអាកាសយានដ្ឋានអន្តរជាតិ ដើម្បីរាយការណ៍ជូនរាជរដ្ឋាភិបាល ។

**មាត្រា ៥.-**

គណៈកម្មាធិការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិ មានលេខាធិការដ្ឋានមួយ ជាជំនួយការ និងមានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី

លេខាធិការដ្ឋាននេះមានទីតាំងនៅទីស្តីការគណៈរដ្ឋមន្ត្រី ។ សមាសភាព ការរៀបចំ និងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋាន ត្រូវកំណត់ដោយសេចក្តីសំរេចរបស់ប្រធានគណៈកម្មាធិការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិ ។

## ជំពូកទី ៤
## ក្រុមប្រតិបត្តិការសន្តិសុខអាកាសយានដ្ឋានអន្តរជាតិ

**មាត្រា ៦.-**

ក្រុមប្រតិបត្តិការសន្តិសុខអាកាសយានដ្ឋានអន្តរជាតិ ជាអង្គភាពស្ថិតក្រោមការដឹកនាំ និងគ្រប់គ្រងផ្ទាល់ពីគណៈកម្មាធិការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិ មានសមាសភាព :

- នាយកអាកាសយានដ្ឋានអន្តរជាតិ ជាមន្ត្រីនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ប្រធាន
- តំណាងក្រសួងការពារជាតិ អនុប្រធាន
- តំណាងសាលាខេត្ត-ក្រុងដែលមានអាកាសយានដ្ឋានអន្តរជាតិ អនុប្រធាន
- តំណាងអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ អនុប្រធាន
- តំណាងនាយកដ្ឋានសន្តិសុខ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល អនុប្រធានប្រចាំការ
- តំណាងបញ្ជាការដ្ឋានកងទ័ពជើងអាកាស សមាជិក
- តំណាងទីចាត់ការគយ និងរដ្ឋាករ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក
- តំណាងនាយកដ្ឋានកាំកុងត្រូល នៃក្រសួងពាណិជ្ជកម្ម សមាជិក
- តំណាងកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក
- តំណាងក្រុមហ៊ុនសេវាកម្មគ្រប់គ្រងចរាចរដែនអាកាសនៃព្រះរាជាណាចក្រកម្ពុជា សមាជិក
- តំណាងក្រុមហ៊ុនសម្បទានអាកាសយានដ្ឋានអន្តរជាតិ សមាជិក ។

សមាសភាពដឹកនាំ នៃក្រុមប្រតិបត្តិការសន្តិសុខអាកាសយានដ្ឋានអន្តរជាតិ ត្រូវកំណត់ដោយសេចក្តីសំរេចរបស់ប្រធានគណៈកម្មាធិការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិ ដោយមានការឯកភាពពីក្រសួង ស្ថាប័នសាមី ។

**មាត្រា ៧.-**

ក្រុមប្រតិបត្តិការសន្តិសុខអាកាសយានដ្ឋានអន្តរជាតិ មានសិទ្ធិ និងភារកិច្ច :

- អនុវត្តយ៉ាងហ្មឹងម៉ាត់ តាមផែនការមេ ស្តីពីកិច្ចការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ នៅអាកាសយានដ្ឋានអន្តរជាតិ ដោយរៀបចំជាផែនការលំអិត កំណត់បែងចែកតំបន់ភូមិសាស្ត្រសំរាប់ ប្រគល់អោយកំលាំង និងមន្ត្រីមានសមត្ថកិច្ចពាក់ព័ន្ធ ទទួលខុសត្រូវ និងធ្វើសកម្មភាពប្រតិបត្តិការ
- លើកវិធានការសំរាប់អនុវត្ត ដោយកំណត់បែងចែកមណ្ឌល តំបន់ សំរាប់ប្រគល់អោយកំលាំង និងមន្ត្រីមានសមត្ថកិច្ចពាក់ព័ន្ធទទួលខុសត្រូវ និងធ្វើសកម្មភាពប្រតិបត្តិការ ដើម្បីបង្កើនការប្រុងប្រយ័ត្ន ការពារ ទប់ស្កាត់ អំពើភេរវកម្ម និងបទល្មើសផ្សេងៗទៀត នៅអាកាសយានដ្ឋានអន្តរជាតិ ដែលអាចកើតឡើងជាយថាហេតុ នៅពេលដែលពុំទាន់មានផែនការមេ ស្តីពីកិច្ចការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ នៅអាកាសយានដ្ឋានអន្តរជាតិ
- ចាត់តាំងបង្កើតអង្គភាពអន្តរាគមន៍ពិសេសសំរាប់ចេញធ្វើសកម្មភាពបន្ទាន់ ពេលមានគ្រោះអាសន្នចៃដន្យ ឬគ្រោះមហន្តរាយ កើតឡើងជាយថាហេតុ ដោយរៀបចំសមាសភាពចំរុះនៃកងយោធពលខេមរភូមិន្ទ កងនគរបាលជាតិ និងកងកំលាំងសន្តិសុខអាកាសចរស៊ីវិល

អោយមានចំនួនសមល្មម ហើយត្រូវធ្វើការហ្វឹកហ្វឺនជំនាញជាប់ជាប្រចាំ និងឆ្លងកាត់ការសាកល្បងធ្វើសមយុទ្ធ

- គ្រប់គ្រង ដឹកនាំកំលាំង ដើម្បីការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ នៅតំបន់ប្រតិបត្តិការអាកាស តំបន់សាធារណៈ តំបន់នៃបន្ទប់ទទួលភ្ញៀវពិសេស តំបន់ស្ថានីយ៍អ្នកដំណើរជាតិ និងតំបន់ស្ថានីយ៍អ្នកដំណើរអន្តរជាតិ ចំណតរថយន្ត ភោជនីយដ្ឋាន ហាងលក់ទំនិញរួចពន្ធ ឃ្លាំងគ្រឿងផ្គត់ផ្គង់ និងតំបន់ផ្សេងៗ ទូទាំងអាកាសយានដ្ឋានអន្តរជាតិ
- ការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ ក្នុង និងជុំវិញអាកាសយានដ្ឋានអន្តរជាតិ ដោយអនុវត្តតាមសន្ធិសញ្ញា អនុសញ្ញា កិច្ចព្រមព្រៀង ស្តីពីវិស័យសន្តិសុខអាកាសចរស៊ីវិលអន្តរជាតិ
- ចាត់ចែងអោយមានការធ្វើតេស្តពិសោធន៍ នៅលើឧបករណ៍មធ្យោបាយបំពាក់នានា ដែលបានដាក់អោយដំណើរការ តាមដំណាក់កាលនីមួយៗជាប្រចាំ នៅក្នុងអាកាសយានដ្ឋានអន្តរជាតិ
- ចាត់តាំងកំលាំងអោយចូលរួមសហការពិនិត្យលើកញ្ចក់ទូរទស្សន៍ នៅមជ្ឈមណ្ឌលកណ្តាលសន្តិសុខ ដែលដំណើរការថតរាល់សកម្មភាពក្នុងដែនដីនៃអាកាសយានដ្ឋានអន្តរជាតិ និងចាត់តាំងកំលាំងនៃក្រុមពន្លត់អគ្គិភ័យ អោយត្រៀមលក្ខណៈសម្បត្តិ ដើម្បីចេញប្រតិបត្តិការបន្ទាន់នានា
- ធ្វើការប្រកាសជូនពត៌មាន ស្តីពីសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ ក្នុង និងជុំវិញអាកាសយានដ្ឋានអន្តរជាតិ ដល់ក្រុមហ៊ុនអាកាសចរស៊ីវិល និងសាធារណជន ក្រោយពីបានការឯកភាពពីប្រធានគណៈកម្មាធិការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិ ។

ទីស្នាក់ការរបស់ក្រុមប្រតិបត្តិការសន្តិសុខអាកាសយានដ្ឋានអន្តរជាតិ មានទីតាំងក្នុងអាកាសយានដ្ឋានអន្តរជាតិនីមួយៗ ។

**មាត្រា ៨.-**

ប្រធានក្រុមប្រតិបត្តិការសន្តិសុខអាកាសយានដ្ឋានអន្តរជាតិ មានភារកិច្ច :

- ទទួលខុសត្រូវក្នុងការដឹកនាំអនុវត្តនូវសិទ្ធិ និងភារកិច្ច របស់ក្រុមប្រតិបត្តិការសន្តិសុខអាកាសយានដ្ឋានអន្តរជាតិ ដូចមានចែងក្នុងមាត្រា ៧ នៃអនុក្រឹត្យនេះ
- ធ្វើជាមេបញ្ជាការ ក្នុងកិច្ចការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ ក្នុង និងជុំវិញអាកាសយានដ្ឋានអន្តរជាតិ ដោយអនុវត្តតាមសន្ធិសញ្ញា អនុសញ្ញា កិច្ចព្រមព្រៀង ស្តីពីវិស័យសន្តិសុខអាកាសចរស៊ីវិលអន្តរជាតិ

- ទាក់ទងជាមួយកំលាំងមានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីដឹកនាំ ត្រៀម និងចាត់វិធានការទប់ស្កាត់ និងដោះស្រាយការប៉ុនប៉ង ឬការរំលោភបំពាន និងបទល្មើសផ្សេងៗមកលើអាកាសយាន និងអាកាសយានដ្ឋាន និងទាក់ទងជាមួយអ្នកជំនាញផ្នែកអាវុធជាតិផ្ទុះ ដើម្បីចាត់ចែងដោះស្រាយចំពោះវត្ថុ សារធាតុសង្ស័យ ឬជាតិផ្ទុះ
- សហការជាមួយក្រុមត្រួតពិនិត្យច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិ និងក្រុមហ៊ុនសម្បទានអាកាសយានដ្ឋានអន្តរជាតិ ដើម្បីគ្រប់គ្រងបន្ទប់ទទួលភ្ញៀវពិសេស សំដៅបង្កើនកិច្ចការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ
- ដឹកនាំដោយផ្ទាល់លើការកំណត់សមាសភាព និងការត្រួតពិនិត្យអ្នកដំណើរ សំភារៈ និងអីវ៉ាន់យួរដៃ នៅស្ថានីយ៍អ្នកដំណើរក្នុងស្រុកនៃអាកាសយានដ្ឋានអន្តរជាតិ ដើម្បីបង្កើនកិច្ចការពារ សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ
- ត្រួតពិនិត្យ សរុបការងារដឹកជញ្ជូនចេញ-ចូល តាមច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិ
- ធ្វើការត្រួតពិនិត្យ និងវាយតំលៃលើរាល់សកម្មភាព ដែលពាក់ព័ន្ធនឹងសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈរៀងរាល់ថ្ងៃ នៅអាកាសយានដ្ឋានអន្តរជាតិ និងប្រជុំក្នុងក្រុមប្រតិបត្តិការសន្តិសុខអាកាសយានដ្ឋានអន្តរជាតិ យ៉ាងតិចមួយខែម្តង។ ក្នុងករណីចាំបាច់អាចប្រជុំជាវិសាមញ្ញ
- បូកសរុបរាយការណ៍អំពីសភាពការណ៍ និងសកម្មភាព នៅអាកាសយានដ្ឋានអន្តរជាតិប្រចាំខែ ត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំ ជូនគណៈកម្មាធិការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិ ទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល និងក្រសួងស្ថាប័នពាក់ព័ន្ធ ។

**មាត្រា ៩.-**

កំលាំងសន្តិសុខ នៃក្រុមប្រតិបត្តិការសន្តិសុខអាកាសយានដ្ឋានអន្តរជាតិ ដែលជាមន្ត្រីរាជការរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល មានភារកិច្ច :

- ទទួលខុសត្រូវក្នុងកិច្ចការពារ និងត្រួតពិនិត្យការងារសន្តិសុខជុំវិញ និងក្នុងអាកាសយានដ្ឋានតាមការកំណត់បែងចែកតំបន់ភូមិសាស្ត្រ របស់ប្រធានក្រុមប្រតិបត្តិការសន្តិសុខអាកាសយានដ្ឋានអន្តរជាតិ
- ត្រួតពិនិត្យប័ណ្ណចេញ-ចូល អាកាសយានដ្ឋាន របស់ក្រុមអាកាសយានិក បុគ្គលិកហោះហើរ មន្ត្រីរាជការនិងកងកំលាំងពាក់ព័ន្ធ និងប័ណ្ណអនុញ្ញាតយានយន្តចេញ-ចូលអាកាសយានដ្ឋានក្នុងតំបន់ដែលគ្រប់គ្រងដោយរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល និងសហការត្រួតពិនិត្យ

ប័ណ្ណចេញ-ចូលអាកាសយានដ្ឋាន នៅតំបន់ស្ថានីយ៍អ្នកដំណើររបស់ក្រុមហ៊ុនសម្បទានអាកាសយានដ្ឋានអន្តរជាតិ

- សហការជាមួយស្ថាប័នមានសមត្ថកិច្ច យាមការពារអាកាសយានរបស់គណៈប្រតិភូជាតិ និងអន្តរជាតិ ដែលឈប់សំចតនៅអាកាសយានដ្ឋានអន្តរជាតិ
- ចូលរួមសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច និងកំលាំងរបស់ក្រុមហ៊ុនសម្បទានអាកាសយានដ្ឋានអន្តរជាតិ ដើម្បីមានវិធានការទប់ស្កាត់រាល់ឧប្បត្តិហេតុដែលកើតឡើងដោយចៃដន្យ និងបង្ក្រាបរាល់បទល្មើសអំពើការរំលោភបំពានដោយខុសច្បាប់ ។

## មាត្រា ១០.-

កំលាំងកងរាជអាវុធហត្ថលើផ្ទៃប្រទេស នៃក្រុមប្រតិបត្តិការសន្តិសុខអាកាសយានដ្ឋានអន្តរជាតិ មានភារកិច្ច :

- សហការជាមួយសមត្ថកិច្ចនានា ដើម្បីជួយរៀបចំការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់-ធ្នាប់សាធារណៈ នៅតាមគោលដៅ មុខសញ្ញា និងតំបន់សំខាន់ៗ ដែលបានកំណត់អោយទទួលខុសត្រូវ
- សហការជាមួយសមត្ថកិច្ចនានា ក្នុងការទប់ស្កាត់ និងបង្ក្រាបរាល់បទល្មើសច្បាប់ វិធានបទបញ្ជាផ្ទៃក្នុង និងបទប្បញ្ញត្តិផ្សេងៗ ជាធរមាន ។

## មាត្រា ១១.-

កំលាំងនគរបាលជាតិ នៃក្រុមប្រតិបត្តិការសន្តិសុខអាកាសយានដ្ឋានអន្តរជាតិ ដែលជាកំលាំងរបស់អគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ មានភារកិច្ច :

- សហការជាមួយសមត្ថកិច្ចនានា ដើម្បីជួយរៀបចំការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ នៅតាមគោលដៅ មុខសញ្ញា និងតំបន់សំខាន់ៗ ដែលបានកំណត់អោយទទួលខុសត្រូវ
- សហការជាមួយសមត្ថកិច្ចនានា ក្នុងការទប់ស្កាត់ និងបង្ក្រាបរាល់បទល្មើសច្បាប់ វិធានបទបញ្ជាផ្ទៃក្នុង និងបទប្បញ្ញត្តិផ្សេងៗ ជាធរមាន ។

## មាត្រា ១២.-

កំលាំងរបស់ ខេមបូឌា អ៊ែរ ត្រេហ្វិក សឺវីស ខមភេនី លីមីធីត នៅអាកាសយានដ្ឋានអន្តរជាតិ មានភារកិច្ច :

- បញ្ជា គ្រប់គ្រង និងធានាសុវត្ថិភាពដល់ការហោះហើរឆ្លងកាត់របស់អាកាសយានគ្រប់ប្រភេទតាមបទដ្ឋានអាកាសវិថី ក្នុងដែនអាកាសនៃព្រះរាជាណាចក្រកម្ពុជា
- បញ្ជា គ្រប់គ្រង និងធានាសុវត្ថិភាពដល់ការហោះហើរ ចុះចត និងហោះឡើង របស់អាកាសយានជាតិ និងអន្តរជាតិ ដែលកំពុងធ្វើសេវាកម្មនៅអាកាសយានដ្ឋានអន្តរជាតិ និងក្នុងស្រុក នៃព្រះរាជាណាចក្រកម្ពុជា
- ប្រមូលចំណូលពីសេវាកម្មនេះ ដើម្បីបង់ចូលថវិការដ្ឋ ស្របតាមកិច្ចព្រមព្រៀង
- សហការផ្សព្វផ្សាយ និងផ្តល់ពត៌មាន ដែលពាក់ព័ន្ធនឹងវិស័យអាកាសចរស៊ីវិលអន្តរជាតិ អោយដល់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ តាមរយៈរដ្ឋលេខាធិការដ្ឋាននៃអាកាសចរស៊ីវិល ក្រុមហ៊ុនអាកាសចរជាតិ និងអន្តរជាតិ និងក្រុមអាកាសយានិក ដែលកំពុងហោះហើរក្នុងបូរណភាពដែនអាកាសនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីធានាសុវត្ថិភាពនៃការហោះហើរ
- បំពេញបែបបទអោយដល់អាកាសយានជាតិ និងអន្តរជាតិ តាមទំរង់បែបបទ និងស្តង់ដានៃជើងហោះហើរនីមួយៗ អោយបានត្រឹមត្រូវ
- ផ្សព្វផ្សាយ ទទួលពត៌មាន ដែលពាក់ព័ន្ធដល់កម្មវិធីនៃការហោះហើរប្រក្រតី និងមិនប្រក្រតីរបស់អាកាសយានគ្រប់ប្រភេទ ។

**មាត្រា ១៣.-**

កំលាំងសន្តិសុខរបស់ក្រុមហ៊ុនសម្បទានអាកាសយានដ្ឋានអន្តរជាតិ ដែលស្ថិតក្រោមការដឹកនាំពីក្រុមប្រតិបត្តិការសន្តិសុខអាកាសយានដ្ឋានអន្តរជាតិ មានភារកិច្ច ៖

- គ្រប់គ្រង ពិនិត្យ និងថែរក្សាទូរទស្សន៍ផតពីសកម្មភាពទាំងអស់ ក្នុងអាកាសយានដ្ឋានអន្តរជាតិ នៅមជ្ឈមណ្ឌលកណ្តាលសន្តិសុខ
- សហការជាមួយសមត្ថកិច្ចនានា ត្រួតពិនិត្យអ្នកដំណើរ សំភារៈ និងអីវ៉ាន់យួរដៃ ដែលបានឆ្លងកាត់ស្ថានីយ៍អ្នកដំណើរក្នុងប្រទេស
- យាមប្រចាំការ ដោយសហការជាមួយកំលាំងមានសមត្ថកិច្ច ក្នុងការទប់ស្កាត់បទល្មើសក្នុងមណ្ឌលដែលបានកំណត់អោយទទួលខុសត្រូវ
- រាយការណ៍អំពីសកម្មភាពមិនប្រក្រតីជាបន្ទាន់ ជូនក្រុមប្រតិបត្តិការសន្តិសុខអាកាសយាន-ដ្ឋានអន្តរជាតិ ។

# ជំពូកទី ៥
## ក្រុមត្រួតពិនិត្យច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិ

**មាត្រា ១៤.-**

ក្រុមត្រួតពិនិត្យច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិ ជាអង្គភាពស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់គណៈកម្មាធិការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិ មានសមាសភាព :

- នាយកអាកាសយានដ្ឋានអន្តរជាតិ ជាមន្ត្រីរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ប្រធាន
- នាយនគរបាលជាតិ នៃនាយកដ្ឋានជនបរទេស អគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ អនុប្រធាន
- មន្ត្រីគយនិងរដ្ឋាករ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុប្រធាន
- មន្ត្រីកាំកុងត្រូល នៃក្រសួងពាណិជ្ជកម្ម សមាជិក
- តំណាងក្រុមហ៊ុនសម្បទាន អាកាសយានដ្ឋានអន្តរជាតិ សមាជិក ។

ចំនួនសហការី នៃក្រុមត្រួតពិនិត្យច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិ ត្រូវកំណត់ដោយសេចក្តីសំរេចរបស់ប្រធានគណៈកម្មាធិការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិ ដោយមានការឯកភាពពីក្រសួង ស្ថាប័នសាមីនីមួយៗ ។

**មាត្រា ១៥.-**

ក្រុមត្រួតពិនិត្យច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិ មានសិទ្ធិ និងភារកិច្ច ធ្វើសកម្មភាពត្រួតពិនិត្យអ្នកដំណើរ សំភារៈ និងទំនិញ នៅស្ថានីយ៍អ្នកដំណើរអន្តរជាតិ និងមជ្ឈមណ្ឌលឃ្លាំងទំនិញ ក្នុងអាកាសយានដ្ឋានអន្តរជាតិ ។

**មាត្រា ១៦.-**

ក្រុមត្រួតពិនិត្យច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិ ចែកចេញជាពីរផ្នែក គឺ :

- ផ្នែកទី១ :

ក្រុមត្រួតពិនិត្យនៅស្ថានីយ៍អ្នកដំណើរអន្តរជាតិ មានសមាសភាព :

- នគរបាលជាតិ នៃនាយកដ្ឋានជនបរទេស អគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ ប្រធាន
- មន្ត្រីគយ និងរដ្ឋាករនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក
- មន្ត្រីកាំកុងត្រូល នៃក្រសួងពាណិជ្ជកម្ម សមាជិក

- មន្ត្រីត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ នៃក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក
- មន្ត្រីភូតគាមអនាម័យ នៃក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ សមាជិក
- កំលាំងសន្តិសុខ នៃក្រុមហ៊ុនសម្បទានអាកាសយានដ្ឋានអន្តរជាតិ សមាជិក

• ផ្នែកទី២ :

ក្រុមត្រួតពិនិត្យនៅមជ្ឈមណ្ឌលឃ្លាំងទំនិញ មានសមាសភាព :

- មន្ត្រីគយ និងរដ្ឋាករ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធាន
- មន្ត្រីកាំកុងត្រូលនៃក្រសួងពាណិជ្ជកម្ម សមាជិក
- មន្ត្រីត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ នៃក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក
- មន្ត្រីភូតគាមអនាម័យ នៃក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ សមាជិក
- កំលាំងសន្តិសុខ នៃក្រុមហ៊ុនសម្បទានអាកាសយានដ្ឋានអន្តរជាតិ សមាជិក

ចំនួនសមាជិកនៃក្រុមត្រួតពិនិត្យ នៅស្ថានីយ៍អ្នកដំណើរអន្តរជាតិ និងមណ្ឌលឃ្លាំងទំនិញ ត្រូវកំណត់ដោយសេចក្តីសំរេចរបស់ប្រធានគណៈកម្មាធិការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិ ដោយមានការឯកភាពពីក្រសួង ស្ថាប័ន សាមីនីមួយៗ ។

**មាត្រា ១៧.-**

ប្រធានក្រុមត្រួតពិនិត្យច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិ មានភារកិច្ច :

- ធ្វើជាអធិបតីក្នុងសម័យប្រជុំនានា របស់ក្រុមត្រួតពិនិត្យច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិ
- ធានាការប្រជុំរួមនៃគ្រប់តំណាងក្រុមហ៊ុននានា កំលាំង និងមន្ត្រីភ្នាក់ងារមានសមត្ថកិច្ច នៃក្រុមត្រួតពិនិត្យច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិ យ៉ាងតិចមួយខែម្តង ។ ក្នុងករណីចាំបាច់ អាចប្រជុំជាវិសាមញ្ញ
- ដឹកនាំគ្រប់អង្គភាព ចំពោះក្រុមត្រួតពិនិត្យច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិ អោយដំណើរការបានត្រឹមត្រូវ ស្របតាមសន្ធិសញ្ញា អនុសញ្ញា កិច្ចព្រមព្រៀងអន្តរជាតិ ស្តីពីវិស័យអាកាសចរស៊ីវិល រដ្ឋធម្មនុញ្ញ ច្បាប់ លិខិតបទដ្ឋាន និងបទបញ្ជាផ្ទៃក្នុង នៃក្រុមត្រួតពិនិត្យច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិ
- សំរបសំរួលការងារក្នុងក្រុមត្រួតពិនិត្យច្រកទ្វារអោយមានភាពរលូន
- ដឹកនាំការងាររបស់ក្រុមត្រួតពិនិត្យច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិ និងរាយការណ៍អំពីសកម្មភាពការងាររបស់គ្រប់កំលាំងនគរបាលជាតិ មន្ត្រីភ្នាក់ងារមានសមត្ថកិច្ច និងបុគ្គលិក

ក្រុមហ៊ុនសម្បទានអាកាសយានដ្ឋានអន្តរជាតិ ទៅគណៈកម្មាធិការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិ និងចំលងជូនក្រសួង ស្ថាប័នសាមី ក្នុងករណីបុគ្គលណា ឬ អង្គភាពណាប្រព្រឹត្តបទល្មើស ។

- ដឹកនាំកិច្ចសហការជាមួយក្រុមប្រតិបត្តិការសន្តិសុខអាកាសយានដ្ឋានអន្តរជាតិ និងសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីធានាការអនុវត្តអោយបានត្រឹមត្រូវតាមសន្ធិសញ្ញា អនុសញ្ញា កិច្ចព្រមព្រៀងអន្តរជាតិ ស្តីពីវិស័យអាកាសចរស៊ីវិល ច្បាប់ លិខិតបទដ្ឋាន និងបទប្បញ្ញត្តិ ជាធរមាន ដើម្បីបង្កើនកិច្ចការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ ក្នុងស្ថានីយ៍អ្នកដំណើរអន្តរជាតិ
- ធ្វើរបាយការណ៍បូកសរុបប្រចាំខែ ត្រីមាស ឆមាស ៩ខែ ប្រចាំឆ្នាំ ផ្ញើជូនគណៈកម្មាធិការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិ ទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ក្រុមប្រតិបត្តិការសន្តិសុខអាកាសយានដ្ឋានអន្តរជាតិ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាលាខេត្ត-ក្រុង ដែលមានអាកាសយានដ្ឋានអន្តរជាតិ ។

**មាត្រា ១៨.-**

មន្ត្រីនគរបាលជាតិនាយកដ្ឋានជនបរទេស នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ ក្នុងក្រុមត្រួតពិនិត្យច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិ មានភារកិច្ច :

- ផ្តល់ និងត្រួតពិនិត្យទិដ្ឋាការអ្នកដំណើរ តាមការកំណត់របស់រាជរដ្ឋាភិបាល
- ត្រួតពិនិត្យអ្នកដំណើរ ចេញ-ចូលប្រទេស ទាំងសញ្ជាតិបរទេស និងសញ្ជាតិខ្មែរ នៅស្ថានីយ៍អ្នកដំណើរអន្តរជាតិ និងបន្ទប់ទទួលភ្ញៀវពិសេស
- សហការដោយសមស្របជាមួយសមត្ថកិច្ចជាប់ ក្នុងការត្រួតពិនិត្យអាកាសយាន និងទំនិញគ្រប់ប្រភេទនៅច្រកទ្វារ និងមណ្ឌលឃ្លាំងទំនិញ ដែលចេញ-ចូល ព្រះរាជាណាចក្រកម្ពុជា សំដៅរកឃើញ និងបង្ក្រាបទាន់ពេលវេលា បទល្មើសឆ្លងដែន ការរត់គេចពន្ធ ការជួញដូរមនុស្ស ការធ្វើចរាចរឬបិយវត្ថុក្លែងក្លាយ ការជួញដូរគ្រឿងញៀន វត្ថុបុរាណ ការដឹកជញ្ជូន ការជួញដូរ ការប្រើប្រាស់អាវុធជាតិផ្ទុះ និងបរិក្ខាសឹកខុសច្បាប់ និងបទល្មើសផ្សេងៗទៀត
- សហការធានាវិធានការ ការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ នៅក្នុងស្ថានីយ៍អ្នកដំណើរអន្តរជាតិ
- ប្រមូលចំណូល ដែលបានមកពីការផ្តល់ទិដ្ឋាការអោយអ្នកដំណើរបរទេសចូលព្រះរាជាណាចក្រកម្ពុជា បង់ចូលថវិការដ្ឋ ។

**មាត្រា ១៩.-**

មន្ត្រីគយ និងរដ្ឋាករ ក្នុងក្រុមត្រួតពិនិត្យច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិ មានភារកិច្ច :

- គ្រប់គ្រង ត្រួតពិនិត្យ និងប្រមូលពន្ធ អាករ ព្រមទាំងកំរៃនានា បង់ចូលថវិការដ្ឋលើទំនិញ និងមធ្យោបាយដឹកជញ្ជូននាំចេញ-នាំចូលគ្រប់ប្រភេទ រួមទាំងអីវ៉ាន់អ្នកដំណើរ កញ្ចប់ ប្រៃសណីយ៍ រូបិយវត្ថុ លោហធាតុ ឬត្បូងថ្ម មានតំលៃ ព្រមទាំងទំនិញ និងសារធាតុ ផ្សេងៗទៀត ដែលមានចែងក្នុងតារាងពន្ធគយ នៃព្រះរាជាណាចក្រកម្ពុជា ស្របតាម នីតិវិធីគយ និងបទប្បញ្ញត្តិច្បាប់ពាក់ព័ន្ធ ផ្សេងទៀតជាធរមាន
- បញ្ជាក់លទ្ធផលនៃការត្រួតពិនិត្យនៅលើប្រតិវេទន៍គយ ហើយក្នុងករណីរកឃើញបទល្មើស គយ ត្រូវធ្វើកំណត់ហេតុនៃបទល្មើសនេះ និងចាត់ចែងឃាត់ ឬរក្សាទុកជាបណ្តោះអាសន្ន នូវទំនិញ ឬមធ្យោបាយល្មើសនេះ រង់ចាំការសំរេចពីស្ថាប័នមានសមត្ថកិច្ច
- ត្រួតពិនិត្យរួមគ្នាជាមួយកំលាំងសន្តិសុខក្រុមហ៊ុនសម្បទានអាកាសយានដ្ឋានអន្តរជាតិ នៅ លើម៉ាស៊ីនកាំរស្មីអ៊ិច នៅពេលភ្នាក់ងារគយ និងរដ្ឋាករ ពុំទាន់បំពាក់ឧបករណ៍ត្រួតពិនិត្យ
- បង្ការ ទប់ស្កាត់ និងបង្ក្រាបរាល់បទល្មើសរត់គេចពន្ធគ្រប់ប្រភេទ ។

**មាត្រា ២០.-**

មន្ត្រីកាំកុងត្រូល នៅក្នុងក្រុមត្រួតពិនិត្យច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិ មានភារកិច្ច :

- ត្រួតពិនិត្យលើបរិមាណ ទំងន់ គុណភាព និងសភាពផលិតផល នៃទំនិញនាំចេញ-នាំចូល និងចេញវិញ្ញាបនប័ត្របញ្ជាក់លើបរិមាណ គុណភាពទំនិញ និងសភាពផលិតផលនៃទំនិញ នាំចេញ-នាំចូល
- លើកវិធានការរាំងខ្ទប់ និងចាប់ឃាត់ទំនិញនាំចេញ-នាំចូល ខូច ឬ អន់គុណភាព និងបង្ក្រាប ការក្លែងបន្លំ
- ប្រមូលប្រាក់កំរៃត្រួតពិនិត្យទំនិញនាំចេញ-នាំចូល ស្របតាមប្រកាសអន្តរក្រសួងរវាងក្រសួង ពាណិជ្ជកម្ម និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីបង់ចូលថវិការដ្ឋ ។

**មាត្រា ២១.-**

មន្ត្រីត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ មានភារកិច្ច ត្រួតពិនិត្យ អនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ និងអនុវត្តវិធានបសុពេទ្យ លើមធ្យោបាយដឹកជញ្ជូន និង ទំនិញដែលជាកម្មវត្ថុនៃការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ ។

**មាត្រា ២២.-**

មន្ត្រីភូតគាមអនាម័យ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានភារកិច្ចធ្វើការត្រួតពិនិត្យ និងអនុវត្តវិធានភូតគាមអនាម័យ លើរាល់ការនាំយក ឬ ដឹកជញ្ជូនទំនិញដែលជាកម្មវត្ថុ នៃការត្រួតពិនិត្យភូតគាមអនាម័យ តាមខ្លឹមសារនៃអនុក្រឹត្យលេខ ១៥ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីការត្រួតពិនិត្យភូតគាមអនាម័យ និងកិច្ចព្រមព្រៀងស្តីពីវិធានការអនាម័យ និងភូតគាមអនាម័យ របស់អង្គការពាណិជ្ជកម្មពិភពលោក ។

**មាត្រា ២៣.-**

ក្រុមហ៊ុនសម្បទានអាកាសយានដ្ឋានអន្តរជាតិ មានភារកិច្ច :

- ចាត់ចែងប្រមូលចំណូល ដែលបានមកពីកំរៃលើសេវាកម្មផ្សេងៗ ហើយបែងចែកភាគផលតាមការកំណត់ក្នុងកិច្ចព្រមព្រៀង រវាងក្រុមហ៊ុនសម្បទានអាកាសយានដ្ឋានអន្តរជាតិ ជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា និងបង់ចូលថវិការដ្ឋអោយបានទៀងទាត់
- ផលិត និងផ្តល់ប័ណ្ណរថយន្ត និងប័ណ្ណចេញ-ចូលអាកាសយានដ្ឋានអន្តរជាតិ អោយដល់កំលាំងមន្ត្រីមានសមត្ថកិច្ច មន្ត្រីរាជការនៃក្រសួង ស្ថាប័ន ភ្នាក់ងារក្រុមហ៊ុនឯកជន និងបុគ្គលសំខាន់ៗផ្សេងទៀត ក្រោយពីមានការឯកភាពលើសមាសភាព និងចំនួនពីគណៈកម្មាធិការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិ។
- បែបបទនៃការស្នើសុំ និងការប្រើប្រាស់ប័ណ្ណខាងលើ ត្រូវកំណត់ដោយសេចក្តីសំរេចរបស់គណៈកម្មាធិការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិ។
- បំពាក់មធ្យោបាយធ្វើការងារ និងឧបករណ៍ត្រួតពិនិត្យ ស្របតាមកិច្ចព្រមព្រៀងជាធរមាន។

**មាត្រា ២៤.-**

កំលាំងសន្តិសុខក្រុមហ៊ុនសម្បទានអាកាសយានដ្ឋានអន្តរជាតិ នៃក្រុមត្រួតពិនិត្យច្រកទ្វារអាកាស-យានដ្ឋានអន្តរជាតិ មានភារកិច្ច :

- យាមប្រចាំការតាមគ្រប់ច្រកទ្វារចេញ-ចូល នៃស្ថានីយ៍អ្នកដំណើរអន្តរជាតិ ដើម្បីរួមសហការជាមួយកំលាំងមានសមត្ថកិច្ចនានា ក្នុងកិច្ចការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ
- សហការជាមួយសមត្ថកិច្ចនានា ក្នុងការទប់ស្កាត់ និងបង្ក្រាបអំពើល្មើសផ្សេងៗ ក្នុងបណ្តូលសំខាន់ៗ ដែលបានកំណត់អោយទទួលខុសត្រូវ
- សហការត្រួតពិនិត្យអ្នកដំណើរ ការចេញ-ចូល ឆ្លងកាត់ ទំនិញ និងអីវ៉ាន់យួរដៃ

របស់អ្នកដំណើរ ដែលឆ្លងកាត់ទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិ និងឆ្លងកាត់មណ្ឌលឆ្លាំងទំនិញ រួមទាំងការផ្ទុកទំនិញលើអាកាសយាន ។

## ជំពូកទី ៦

## បន្ទប់ទទួលភ្ញៀវពិសេស

**មាត្រា ២៥.-**

និតិវិធី បែបបទនៃការចេញ-ចូល និងការធ្វើអាជីវកម្ម សេវាកម្មនៅបន្ទប់ទទួលភ្ញៀវពិសេស ត្រូវកំណត់ដោយសេចក្តីសំរេចរបស់គណៈកម្មាធិការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិ ដោយមានការឯកភាពពីក្រុមហ៊ុនសម្បទានអាកាសយានដ្ឋានអន្តរជាតិ ។

**មាត្រា ២៦.-**

ក្រុមហ៊ុនសម្បទានអាកាសយានដ្ឋានអន្តរជាតិ ជាអ្នកទទួលខុសត្រូវលើការងារគ្រប់គ្រងការធ្វើអាជីវកម្ម សេវាកម្មនានា និងលើការងារសាងសង់ ថែទាំ ជួសជុល កែលំអសោភ័ណភាព អោយមានលក្ខណៈទំនើប ធានារក្សាបាននូវស្ថាបត្យកម្ម និងវប្បធម៌ជាតិខ្មែរ នៅបន្ទប់ទទួលភ្ញៀវពិសេសនៃអាកាសយានដ្ឋានអន្តរជាតិ ។

**មាត្រា ២៧.-**

ក្រុមប្រតិបត្តិការសន្តិសុខអាកាសយានដ្ឋានអន្តរជាតិ គ្រប់គ្រង និងដឹកនាំផ្ទាល់លើការងារការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់ នៅក្នុង និងជុំវិញបន្ទប់ទទួលភ្ញៀវពិសេស ។

**មាត្រា ២៨.-**

សមត្ថកិច្ចត្រួតពិនិត្យនៅបន្ទប់ទទួលភ្ញៀវពិសេស នៃអាកាសយានដ្ឋានអន្តរជាតិ មានសមាសភាព :

- កំលាំងសន្តិសុខអាកាសយានដ្ឋានអន្តរជាតិ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ប្រធាន
- កំលាំងនគរបាលជាតិ នាយកដ្ឋានជនបរទេស នៃអគ្គស្នងការដ្ឋាននគរបាលជាតិ អនុប្រធាន
- មន្ត្រីគយនិងរដ្ឋាករ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក
- មន្ត្រីកាំកុងត្រូល នៃក្រសួងពាណិជ្ជកម្ម សមាជិក
- កំលាំងសន្តិសុខក្រុមហ៊ុនសម្បទានអាកាសយានដ្ឋានអន្តរជាតិ សមាជិក

ចំនួនសហការី នៃសមត្ថកិច្ចក្រុមត្រួតពិនិត្យនៅបន្ទប់ទទួលភ្ញៀវពិសេស ត្រូវកំណត់ដោយសេចក្តីសំរេចរបស់គណៈកម្មាធិការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិ ដោយមានការឯកភាពពីក្រសួង ស្ថាប័នសាមី ។

**មាត្រា ២៩.-**

កំលាំងនគរបាលជាតិ នាយកដ្ឋានជនបរទេស នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ មន្ត្រីគយ និងរដ្ឋាករនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងមន្ត្រីកាំកុងត្រូលនៃក្រសួងពាណិជ្ជកម្ម នៅបន្ទប់ទទួលភ្ញៀវពិសេស មានភារកិច្ច ដូចមានចែងក្នុងមាត្រា ១៨ . ១៩ និង ២០ នៃអនុក្រឹត្យនេះ ។

**មាត្រា ៣០.-**

កំលាំងសន្តិសុខអាកាសយានដ្ឋានអន្តរជាតិ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល និងកំលាំងសន្តិសុខក្រុមហ៊ុនសម្បទាន នៃអាកាសយានដ្ឋានអន្តរជាតិ នៅបន្ទប់ទទួលភ្ញៀវពិសេស មានភារកិច្ច :

- ធានាការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ ជូនគណៈប្រតិភូជាតិ អន្តរជាតិ និងភ្ញៀវពិសេសផ្សេងៗ ទៀត
- សហការត្រួតពិនិត្យអ្នកដំណើរ សំភារៈ និងអីវ៉ាន់យួរដៃ របស់សមាជិកគណៈប្រតិភូជាតិ អន្តរជាតិ និងភ្ញៀវពិសេសផ្សេងៗទៀត ។

## ជំពូកទី ៧

## សមត្ថកិច្ចអាជ្ញាធរដែនដី

**មាត្រា ៣១.-**

អភិបាលខេត្ត-ក្រុងសាមី ដែលមានអាកាសយានដ្ឋានអន្តរជាតិ មានភារកិច្ច :

- ទទួលអនុវត្តបទបញ្ជារបស់រាជរដ្ឋាភិបាល និងគណៈកម្មាធិការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិ ស្តីពីការងារដែលពាក់ព័ន្ធនឹងសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ នៅតំបន់ជុំវិញអាកាសយានដ្ឋានអន្តរជាតិ
- បង្ក្រាប និងលុបបំបាត់កំលាំងត្រួតពិនិត្យអនាធិបតេយ្យ ក្នុងដែនដី គ្រប់គ្រងរបស់ខ្លួន និងនៅតំបន់ជុំវិញអាកាសយានដ្ឋានអន្តរជាតិ ។

## ជំពូកទី ៨

## ភារកិច្ចផ្សេងៗ

**មាត្រា ៣២.-**

មន្ត្រីភ្នាក់ងារ កំលាំងមានសមត្ថកិច្ចគ្រប់ជំនាញ និងកំលាំងរបស់ក្រុមហ៊ុនសម្បទាននៅអាកាសយានដ្ឋានអន្តរជាតិ ត្រូវធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំ ជូនក្រសួង ស្ថាប័ន ក្រុមហ៊ុន

សាមី ប្រធានក្រុមប្រតិបត្តិការសន្តិសុខអាកាសយានដ្ឋានអន្តរជាតិ និងប្រធានក្រុមត្រួតពិនិត្យច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិ ។

**មាត្រា ៣៣.-**

មន្ត្រីភ្នាក់ងារ កំលាំងមានសមត្ថកិច្ច និងកំលាំងរបស់ក្រុមហ៊ុនសម្បទានអាកាសយានដ្ឋានអន្តរជាតិទាំងអស់ ដែលបំរើការនៅក្រុមត្រួតពិនិត្យច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិ និងបន្ទប់ទទួលភ្ញៀវពិសេស ត្រូវសហការធ្វើការត្រួតពិនិត្យ ស្របពេលជាមួយគ្នាតាមជំនាញ និងដោយឆាប់រហ័សតាមទំហំការងារនៅកន្លែងតែមួយ ដោយហាមឃាត់មិនអោយមានការបើកឆែកទំនិញ លើសពីមួយដង សំរាប់រយៈពេលឆ្លងកាត់ច្រកទ្វារទាំងមូល ។ ក្នុងករណីមន្ត្រីភ្នាក់ងារមានសមត្ថកិច្ច ឬកំលាំងណាពុំបានចូលរួមត្រួតពិនិត្យតាមការកំណត់របស់ប្រធានក្រុមត្រួតពិនិត្យច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិទេនោះ គឺត្រូវចាត់ទុកថាបានត្រួតពិនិត្យរួចហើយ ។

**មាត្រា ៣៤.-**

មន្ត្រីភ្នាក់ងារ និងកំលាំងមានសមត្ថកិច្ច បំរើការនៅច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិ ត្រូវមានវត្តមាន អនុវត្តភារកិច្ចរបស់ខ្លួននៅជាប់ៗគ្នា ដើម្បីសំរួលការងារក្នុងការបំពេញបែបបទដល់អ្នកដំណើរ និងម្ចាស់ទំនិញអោយបានឆាប់ ។

**មាត្រា ៣៥.-**

ប្រធានភ្នាក់ងារមានសមត្ថកិច្ចជំនាញ និងប្រធាននៃកងកំលាំងនីមួយៗ ត្រូវបែងចែកវេនប្រចាំការតាមទីតាំង គោលដៅ មណ្ឌល តំបន់ និងភូមិសាស្ត្រអោយទទួលខុសត្រូវ នៅអាកាសយានដ្ឋានអន្តរជាតិ ព្រមទាំងត្រូវប្រគល់ភារកិច្ចអោយបានច្បាស់លាស់ដល់មន្ត្រីភ្នាក់ងារ និងកំលាំងរបស់ខ្លួន គិតទាំងថ្ងៃបុណ្យជាតិ និងការឈប់សំរាកផ្សេងៗ អោយបានសមស្របតាមស្ថានភាពជាក់ស្តែង ដើម្បីធានានិរន្តរភាពការងារ ។

**មាត្រា ៣៦.-**

ការងារហ្វឹកហ្វឺន និងការបណ្តុះបណ្តាលវិជ្ជាជីវៈជំនាញ ដើម្បីពង្រឹង ពង្រីកសមត្ថភាពបំពេញការងាររបស់មន្ត្រីភ្នាក់ងារមានសមត្ថកិច្ច និងកំលាំងការពារសន្តិសុខ នៅក្នុងអាកាសយានដ្ឋានអន្តរជាតិនីមួយៗ ជាបន្ទុកថវិការបស់ក្រុមហ៊ុនសម្បទានអាកាសយានដ្ឋានអន្តរជាតិ ។

## ជំពូកទី ៩
## យន្តការអន្តរាគមន៍

**មាត្រា ៣៧.-**

កងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ កងនគរបាលជាតិ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ អាជ្ញាធរដែនដី មន្ត្រីចត្តាឡីស័ក មន្ត្រីត្រួតពិនិត្យឱសថ នៃក្រសួងសុខាភិបាល និងសមត្ថកិច្ចពាក់ព័ន្ធ ដែលមានទីតាំងនៅជិតអាកាសយានដ្ឋានអន្តរជាតិ ត្រូវចេញធ្វើអន្តរាគមន៍ជាបន្ទាន់ តាមតួនាទី និងភារកិច្ចរបស់ក្រសួង ស្ថាប័ន និងអង្គភាពសាមី ក្នុងពេលដែលមានសំណូមពរពីប្រធានគណៈកម្មាធិការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិ ។

ក្នុងករណីមានកើតជម្ងឺឆ្លងរាលដាលក្នុងផ្ទៃប្រទេស និងអន្តរជាតិ ឬពេលមានគ្រោះមហន្តរាយធ្ងន់ធ្ងរកើតឡើង រាជរដ្ឋាភិបាលនឹងចេញបទបញ្ជាដល់មន្ត្រីភ្នាក់ងារ និងកងកំលាំងប្រដាប់អាវុធគ្រប់ប្រភេទ នៃក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ អោយចេញធ្វើអន្តរាគមន៍បំពេញបេសកកម្មនៅអាកាសយានដ្ឋានអន្តរជាតិ តាមករណីជាក់ស្តែងនីមួយៗ ។

## ជំពូកទី ១០
## ទោសប្បញ្ញត្តិ

**មាត្រា ៣៨.-**

កងកំលាំង និងមន្ត្រីភ្នាក់ងារមានសមត្ថកិច្ចនៃក្រសួង ស្ថាប័ន និងអង្គភាព ដែលបានចាត់បញ្ជូនមកអោយប្រចាំការ ឬបំពេញបេសកកម្មការងារនៅក្នុងអាកាសយានដ្ឋានអន្តរជាតិ ហើយដែលបានឆ្លៀតប្រើប្រាស់តួនាទីភារកិច្ច និងសិទ្ធិអំណាចរបស់ខ្លួន បង្កអោយមានការលំបាកដល់អាកាសយាននៃក្រុមហ៊ុនអាកាសចរនានា អ្នកដំណើរ និងការឆ្លងកាត់នៃទំនិញគ្រប់ប្រភេទ នៅអាកាសយានដ្ឋានអន្តរជាតិ ដោយគ្មានមូលហេតុស្របច្បាប់ ឬរំលោភបំពានសមត្ថកិច្ចដទៃ ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

## ជំពូកទី ១១
## អវសានប្បញ្ញត្តិ

**មាត្រា ៣៩.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៤០.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃក្រសួង ស្ថាប័ន និងអភិបាល ខេត្ត-ក្រុងពាក់ព័ន្ធ និងក្រុមហ៊ុនសម្បទានអាកាសយានដ្ឋានអន្តរជាតិ ព្រមទាំងសមាសភាពដូចមានចែងក្នុងមាត្រា៣ មាត្រា៦ មាត្រា១៤ មាត្រា១៦ មាត្រា២៨ និងមាត្រា៣៧ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤០
- ឯកសារ-កាលប្បវត្តិ